# ការរាយការណ៍ផ្ទាល់មាត់ជូនគណៈកម្មាធិការ CEDAW

១. សូមគោរពលោកស្រីប្រធាន និងសមាជិកគណៈកម្មាធិការ យើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណដល់លោកស្រី និងសមាជិកទាំងអស់ ដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំបានថ្លែងនូវមតិយោបល់នៅថ្ងៃនេះ។ យើងខ្ញុំសូមថ្លែងតាំងនាមអោយអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងអង្គការសិទ្ធិមនុស្សនានាដែលធ្វើការដើម្បីសិទ្ធិមនុស្សរបស់ស្ត្រី ព្រមទាំងអ្នកដែលបន្តឃ្លាំមើលការអនុវត្តន៍អនុសញ្ញា CEDAW នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏សូមថ្លែងជំនួសឲ្យសហាសេវិកាជាច្រើនទៀតដែលត្រូវបានគេបំបិទសំលេង មិនថាអ្នកទាំងនោះកំពុងជាប់ពន្ធនាគារ ឬបានបាត់បង់ជីវិតទៅហើយក៏ដោយ។

២. បើទោះជាមានបញ្ហាជាច្រើនបានកើនឡើងយ៉ាងណាក្តី ក៏យើងខ្ញុំនៅតែផ្តោតការយកចិត្តទុកដាក់ទៅលើៈ ការទទួលបានយុត្តិធម៌ ការបណ្តេញចេញដោយបង្ខំ និង ស្ត្រីរស់នៅជនបទ នយោបាយ និង ជីវភាពសាធារណៈ ការទទួលបានសេវាថែទាំសុខភាពដល់ស្ត្រីដែលផ្ទុកមេរោគអេដ៍ និងជម្ងឺអេដ៍ អំពើហិង្សាលើស្ត្រីភេទ និងកិច្ចគាំពារស្ត្រីនៅកន្លែងការងារ។

## ការទទួលបានយុត្តិធម៌

៣. នៅប្រទេសកម្ពុជា ការយល់ដឹងពីយេនឌ័រក្នុងប្រព័ន្ធតុលាការនៅតែមានការខ្វះខាត។ ជាទូទៅ ស្ត្រីដែលស្វែងរកដំណោះស្រាយតាមប្រព័ន្ធតុលាការតែងតែរងនូវការវិនិច្ឆ័យលំអៀងពីសហាគមន៍ ប្រពៃណី វប្បធម៌ និងសង្គម។ ស្ត្រីជាច្រើនខ្វះទំនុកចិត្តក្នុងការទាមទារនូវសិទ្ធិរបស់ខ្លួន ឬប្រើប្រាស់នីតិវិធីនៃការដាក់ពាក្យបណ្តឹង។ អំពើពុករលួយ ការអសមត្ថភាព និងកង្វះភាពឯករាជ្យរឹតតែបង្កើតនូវការយល់ឃើញពីភាពមិនសំខាន់នៃការប្រើប្រាស់ប្រព័ន្ធតុលាការ។ មូលហេតុទាំងនេះហើយ ដែលបណ្តាលឲ្យស្ត្រីមានអារម្មណ៍ស្ទាក់ស្ទើរមិនហានទទួលយកដំណើរការជំនុំជំរះក្តីដែលមានតម្លៃថ្លៃ និងប្រកបដោយការគម្រាមកំហែងនេះទេ។

៤. អនុសញ្ញា CEDAW កម្រត្រូវបានលើកមកធ្វើជាសំអាងនៅក្នុងបន្ទប់កាត់ក្តីណាស់។ យើងនៅតែមានការព្រួយបារម្ភណ៍ពីកង្វះការប្រើប្រាស់អនុសញ្ញា CEDAW នៅក្នុងប្រព័ន្ធច្បាប់នៅក្នុងប្រទេស ដោយសារការចាត់វិធានការដើម្បីឆ្លើយតបទៅនឹងសេក្តីអង្កេតសន្និដ្ឋានពាក់ព័ន្ធនឹងនិយមន័យនៃការរើសអើង និងធានាថាអនុសញ្ញាស៊ី ដរ ត្រូវបានអនុវត្ត

ពេញលេញនៅក្នុងប្រព័ន្ធច្បាប់ក្នុងប្រទេស (កថាខណ្ឌទី ១០ ១១ និង ១២ ក្នុងសម័យប្រជុំលើកទី៣៤ របស់គណៈកម្មាធិការនេះ)។

---

## ក្របខ័ណ្ឌច្បាប់ និងការអនុវត្តអនុសញ្ញា

១០. គណៈកម្មាធិការកត់សម្គាល់ ដោយកង្វល់នូវចម្លើយតបរបស់គណៈប្រតិភូ ដែលថារដ្ឋភាគីយល់ ថា វាពុំមានការចាំបាច់ក្នុងការកែប្រែច្បាប់របស់ខ្លួនតាមរយៈការប្រើប្រាស់នូវនិយមន័យដ៏គ្រប់ ជ្រុងជ្រោយនៃការរើសអើង ដែលហាមឃាត់នូវការរើសអើងដោយផ្ទាល់ និងដោយប្រយោល។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ ដោយរដ្ឋភាគីពុំទាន់មានសំណុំរឿងណាមួយពាក់ព័ន្ធនឹងការរើសអើងលើស្ត្រីនៅក្នុង តុលាការរបស់រដ្ឋភាគីនៅឡើយ។

**១១. គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថា ខ័ណ្ឌទី១២) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីពិចារណាលើការអនុវត្តក្របខណ្ឌច្បាប់គ្រប់គ្រង សមភាពយេនឌ័រដែលគួរតែបញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រី ដែលគ្របដណ្តប់លើការ រើសអើងដោយផ្ទាល់ និងដោយប្រយោលស្របតាមមាត្រា១នៃអនុសញ្ញា។ គណៈកម្មាធិការ បញ្ជាក់ឡើងវិញលើអនុសាសន៍លើកមុន របស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១០) ដែលស្នើឲ្យរដ្ឋភាគីពង្រឹងវិធានការរបស់ខ្លួនក្នុងការ បង្កើតការយល់ដឹងអំពីអនុសញ្ញា និងពិធីសារ តាមជម្រើសក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមេធាវី និងបន្តបញ្ចូលការបណ្តុះបណ្តាល ស្តីពីអនុសញ្ញាក្នុងកម្មវិធីអប់រំពាក់ព័ន្ធសម្រាប់មន្ត្រីរាជការ មន្ត្រីតុលាការ និងអ្នកដែលបានប្រើ ប្រាស់ក្នុងប្រព័ន្ធអប់រំ។**

## ជំនួយផ្នែកច្បាប់ និងការទទួលបានយុត្តិធម៌

១២. គណៈកម្មាធិការមានកង្វល់អំពីរបាយការណ៍ ដែលលើកឡើងថារដ្ឋភាគីខ្វះប្រព័ន្ធជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយ ដែលប្រការនេះ មានឥទ្ធិពលជាអវិជ្ជមានទៅលើការទទួលបានយុត្តិធម៌ សម្រាប់ស្ត្រី ហើយស្ត្រីត្រូវចំណាយប្រាក់បន្ថែមទៅលើតុលាការ ដោយសារការប្រព្រឹត្តអំពើពុករលួយនៅពេលដំណើរការរឿងក្តីរបស់ពួកគេ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ ដោយ ជំនួយផ្នែកច្បាប់ភាគច្រើនត្រូវបានផ្តល់ ដោយអង្គការមិនមែនរដ្ឋាភិបាល ហើយថវិកាដែលផ្តល់ ដោយរដ្ឋភាគីដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់បម្រើគោលបំណងនេះ មាន ចំនួនមិនគ្រប់គ្រាន់។

## ៥. យើងស្នើឲ្យគណៈកម្មាធិការនេះពិចារណាលើអនុសាសន៍ដូចខាងក្រោម:

*១. ចាត់វិធានការកែទម្រង់ច្បាប់ និងស្ថាប័នដើម្បីធានាថាស្ត្រីទទួលបានយុត្តិធម៌នៅគ្រប់កំរិតនៃប្រព័ន្ធយុត្តិធម៌នេះ។*

*២. អនុម័តច្បាប់ស្តីពីលក្ខខន្តិកៈនៃអង្គចៅក្រម ការប្រព្រឹត្តទៅនៃតុលាការ និងការកែទម្រង់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។*

*៣. ធានាឲ្យមាននូវការប្រើប្រាស់វិធីសាស្ត្រដោះស្រាយបញ្ហាយេនឌ័រ (gender sensitive*

*approaches)នៅក្នុងការអនុវត្តន៍ក្របខណ្ឌច្បាប់ដែលមានស្រាប់ រួមបញ្ចូលទាំងការផ្តល់ជំនួយផ្នែកច្បាប់ផងដែរ។*

## ការបណ្តេញចេញដោយបង្ខំ និងស្ត្រីរស់នៅជនបទ

៦. ការបណ្តេញចេញដោយបង្ខំ និងការរំលោភយកដីធ្លីនៅតែបន្តរីករាលដាល ហើយផ្តល់ផលប៉ះពាល់ដល់ប្រជាជនកម្ពុជាជាង ៧០០,០០០ នាក់ នៅក្នុងរយៈពេលតែមួយទស្សវត្តចុងក្រោយនេះ បង្កើតឲ្យមានស្ថានភាពទីទ័លក្រកាន់តែខ្លាំងដល់ប្រជាពលរដ្ឋគ្មានដែលដីធ្លីដោយមិនមានមធ្យោបាយចិញ្ចឹមជីវិតឲ្យបានគ្រប់គ្រាន់។ ការបណ្តេញចេញដោយបង្ខំផ្តល់ផលប៉ះពាល់ខ្លាំងបំផុតលើស្ត្រីដែលមកបោះតង់នៅទីលំថ្មីនៅក្នុងតំបន់មិនមានការអភិវឌ្ឍន៍ដើម្បីការពារខ្លួន និងកូនៗរបស់ពួកគេនៅពេលស្វាមីចេញទៅប្រកបរបរ ធ្វើចំណាកស្រុក ឬចាកចេញដោយឥតមូលហេតុ។ ប្រហែលជា ២២% នៃផ្ទៃដីកម្ពុជាត្រូវបានផ្តល់ជាដីសម្បទានឲ្យក្រុមហ៊ុនឯកជនដែលបង្កើតប្រាក់ចំណូលតិចតួច ឬគ្មានទាល់តែសោះទៅឲ្យរដ្ឋ ប៉ុន្តែការផ្តល់ដីសម្បទាននេះបានផ្តល់ផលប្រយោជន៍ដល់ក្រុមអ្នកមានឥទ្ធិពលពីគណបក្សកាន់អំណាចទៅវិញ។ បញ្ហាដែលបង្កពីការបំផ្លាញដ៏ធ្ងន់ធ្ងរលើជីវចំរុះ និងប្រព័ន្ធអេកូឡូស៊ី បានប៉ះពាល់ដល់ស្ត្រីរស់នៅជនបទ ពិសេសដល់ស្ត្រីជនជាតិដើមភាគតិច បញ្ហារបស់ស្ត្រីទាំងអស់នេះមិនត្រូវបានយកចិត្តទុកដាក់នោះទេ។ ជាក់ស្តែង សហគមន៍ជនជាតិដើមភាគតិចដែលមានស្ត្រីជាមេកុលសម្ព័ន្ធជាយូរលង់ណាស់មក ហើយកំពុងស្ថិតក្នុងស្ថានភាពប្រឈមនឹងការបាត់បង់ប្រពៃណីវប្បធម៌របស់ពួកគេ។

## អនុសាសន៍

៧. **យើងស្នើឲ្យគណៈកម្មាធិការនេះពិចារណាលើអនុសាសន៍ដូចខាងក្រោម:**

*១. សើរើឡើងវិញលើបញ្ហារំលោភយកដីធ្លី ការបំផ្លាញបរិស្ថានដ៏ធ្ងន់ធ្ងរ និងការបណ្តេញចេញដោយបង្ខំ ដោយផ្តល់ឲ្យប្រជាពលរដ្ឋនូវសិទ្ធិទទួលបានការកាន់កាប់ដីធ្លីបន្ថែមទៀត ព្រមទាំងបង្កើនជំនួយផ្ទាល់ និងសេវាកម្មដែលចាំបាច់ផ្សេងៗ នៅក្នុងសហគមន៍នៃអ្នកតាំងទីលំនៅថ្មីដែលមានមកដល់ពេលនេះ។*

## នយោបាយ និងជីវិតពសាធារណៈ

៨. មិនសូវមានស្ត្រីច្រើនធ្វើជាតំណាងនៅក្នុងជីវិតសាធារណៈ។ នៅក្នុងការបោះឆ្នោតថ្នាក់ជាតិថ្មីៗនេះ ចំនួនតំណាងរាស្ត្រជាស្ត្រីបានធ្លាក់ចុះដល់ ២០%។ នៅក្នុងការបោះឆ្នោតឃុំ

សង្កាត់ចុងក្រោយនេះមានស្ត្រីត្រឹមតែ ១៨% ដែលជាបេក្ខជនជាប់ឆ្នោត។ បើទោះជារដ្ឋាភិបាលបានកំណត់ចំនួនកូតាសំរាប់ការចូលរួមរបស់ស្ត្រីនៅតាមរដ្ឋបាលមូលដ្ឋានក៏ដោយ តែធាតុពិតជាក់ស្តែង អំណាច និងឥទ្ធិពលរបស់ស្ត្រីដែលគេផ្តល់មកឲ្យទាំងនេះ នៅមានកំរិតនៅឡើយ។

៩. បើទោះជាច្បាប់ប្រពៃណីប្រកបដោយការរើសអើងដែលហៅថា (ច្បាប់ស្រី) ត្រូវបានដកចេញពីកម្មវិធីសិក្សាក៏ដោយ ក៏ឥរិយាបថរើសអើងលើភេទនៅតែចាក់ឫសយ៉ាងជ្រៅទៅក្នុងប្រពៃណីវប្បធម៌ដដែល ហើយឥរិយាបថរើសអើងនេះដាក់កំហិតទៅលើស្ត្រីក្នុងកំរិតមួយធំធែង ពិសេសលើស្ត្រីនៅទីជនបទដែលជាទីកន្លែងរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើន។

១០. នៅពេលដែលបញ្ហាមិនទទួលបានការអប់រំត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធិភាព នោះតួនាទីនៅក្នុងជីវិតសាធារណៈក៏អាចកើនឡើងបាន និងអាចបំបាត់នូវឥរិយាបថរើសអើងនានាផងដែរ។ យើងនៅតែមានក្តីបារម្ភចំពោះអត្រាបោះបង់ចោលការសិក្សារបស់ក្មេងស្រី ពិសេសក្មេងស្រីមានអាយុច្រើនបន្តិចដែលជាអ្នកប្រឈមនឹងការរងសម្ពាធឲ្យចូលធ្វើការ ឬឲ្យរៀបការ។

១១. គណៈកម្មាធិការនេះលើកពីបញ្ហានៃការប្រើប្រាស់ប្រព័ន្ធសារព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងបញ្ហានៃការបន្តកង្វះនូវកម្មវិធី និងគោលនយោបាយសកម្មនានាក្នុងគោលបំណងជំរុញលើកទឹកចិត្តដល់ស្ត្រីដែលគ្មានផ្នត់គំនិតរើសអើង ឬដោះស្រាយបញ្ហាដែលពុំសូវមានស្ត្រីជាតំណាងក្នុងតួនាទីផ្នែកសារព័ត៌មាន។ បណ្តាញសារព័ត៌មានមិនទាន់ត្រូវបានយកមកប្រើប្រាស់ធ្វើជាយុទ្ធសាស្ត្រដើម្បីលប់បំបាត់ការរើសអើងយេនឌ័រប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ។

## អនុសាសន៍

១២. **យើងស្នើឲ្យគណៈកម្មាធិការនេះពិចារណាលើអនុសាសន៍ដូចខាងក្រោម:**

*១. បង្កើនកម្មវិធីនានាបន្ថែមដើម្បីពង្រឹងសមត្ថភាពរបស់ស្ត្រី និងចំនួនស្ត្រីនៅក្នុងជួររដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។*

*២. បង្កើតកម្មវិធីនានាដែលជួយគាំទ្រដោយរដ្ឋាភិបាលដើម្បីដោះស្រាយយ៉ាងសកម្មទៅលើបញ្ហានៃឥរិយាបថរើសអើងផ្សេងៗ។*

*៣. បង្កើនការយកចិត្តទុកដាក់ និងបន្តឹងការត្រួតពិនិត្យលើការទទួលបានការអប់រំដោយមានគុណភាពរបស់កុមារី ពិសេសនៅកំរិតអនុវិទ្យាល័យ និងនៅកំរិតសិក្សាកាន់តែខ្ពស់ឡើងៗ។*

*៤. បញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់សសរស្តុំទាំងអស់នៃគោលនយោបាយជាតិខាងផ្នែកពត៌មានវិទ្យា និងគមនាគមន៍ (ICT) និងធ្វើសមាហរណកម្មការយល់ដឹងអំពីយេនឌ័រទៅក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈខាងផ្នែកសារព័ត៌មាន។*

*៥. ចាត់វិធានការដើម្បីបង្កើនការទទួលបាន និងការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីជាក់លាក់ក្នុងបណ្តាញសារព័ត៌មាន។*

## ការផ្តល់សេវាថែទាំសុខភាពដល់ស្ត្រីផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍

**១៣.** ស្ត្រីផ្ទុកមេរោគអេដ៍ និងជម្ងឺអេដ៍នៅតែបន្តរងការរើសអើងពីបុគ្គលិកពេទ្យ រួមមានការទទួលបានការផ្តល់យោបល់មិនឲ្យមានកូន និងត្រូវបានណែនាំឲ្យទទួលយកការគ្រៀរមេជីវិត។ ថ្នាំពន្យាជាញឹកញាប់ហួសកំណត់ប្រើប្រាស់ និងការព្យាបាលមានតម្លៃខ្ពស់។ជាទូទៅអ្នកប្រកបរបរផ្លូវភេទដែលមានផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ដែលត្រូវគេបង្ខាំងទុក មិនទទួលបានការព្យាបាលនោះទេ។ ការប្រើប្រាស់ស្រោមអនាម័យដោយរាប់ទាំងអ្នកប្រកបរបរផ្លូវភេទនៅតែមានកំរិតទាបគួរឲ្យព្រួយបារម្ភនៅឡើយ។

## អំពើហឹង្សាលើស្ត្រី

**១៤.** ការសិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ ២០១៣ របស់ UN ដៃគូរដើម្បីការបង្ការ បង្ហាញថា មានបុរសចំនួន ៣២.៨% ត្រូវបានគេរាយការណ៍ថា បានប្រើអំពើហឹង្សាផ្លូវភេទ និងរាងកាយលើដៃគូររបស់ខ្លួន និងមានបុរសជាង ៥០% ត្រូវបានរាយការណ៍ថាបានប្រើអំពើហឹង្សាផ្លូវចិត្ត និងសេដ្ឋកិច្ច។ ការសិក្សាស្រាវជ្រាវនៅឆ្នាំ ២០០៩ ដោយក្រសួងកិច្ចការនារីបានបង្ហាញថា ជាង ៥០% នៃអ្នកផ្តល់ចម្លើយទាំងអស់យល់ឃើញថា ប្រពន្ធមានអកប្បកិរិយាចូលចិត្តរករឿងគ្មានការគោរព ឬមិនស្តាប់បង្គាប់គឺជាដើមហេតុនាំឲ្យមានអំពើហិង្សា ដែលជាការតបតពីប្តីរបស់ខ្លួន។

**១៥.** ការសិក្សាស្រាវជ្រាវនេះសឲ្យឃើញនូវទំនាក់ទនងយេនឌ័រមិនស្មើភាពគ្នា និងបានកប់ឫសយ៉ាងជ្រៅពិបាកនឹងផ្លាស់ប្តូរ និងត្រូវបានច្រានបន្ថែមទៀតដោយការគ្របសង្កត់ និងការត្រួតត្រារបស់បុរស ដែលជាហេតុបន្តជំរុញឲ្យឥរិយាបថទាំងនេះឈានទៅដល់ការប្រើអំពើ

ហិង្សា។ ទាំងបុរស និងស្ត្រីបានរាយការណ៍ថា ឥរិយាបថរបស់ស្ត្រីត្រូវទទួលរងឥទ្ធិពលយ៉ាងខ្លាំងដោយកង្វះការអនុវត្តន៍ច្បាប់។ មានបញ្ហាជាច្រើនដែលធ្វើការដោះស្រាយនៅថ្នាក់មូលដ្ឋានដោយផ្តោតទៅលើការផ្សះផ្សាអោយជានាជាប្តីប្រពន្ធនឹងគ្នាវិញ ឬការចាត់ចែងបែងចែកហិរញ្ញវត្ថុក្នុងចំណោមភាគីទាំងសងខាង ជារឿយៗមិនបានគិតគូពីសេចក្តីប្រាថ្នា គំនិតយោបល់ ឬទំហំនៃការរងទុក្ខរបស់ស្ត្រីឡើយ។ ស្ថិតិជាច្រើនមិនភាពត្រឹមត្រូវពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ។

១៦. យើងសូមសង្កត់ធ្ងន់ថា បច្ចុប្បន្នមិនទាន់មានកម្មវិធីរបស់រដ្ឋាភិបាលណាមួយ ដើម្បីដោះស្រាយការបំផ្លិចបំផ្លាញដែលទទួលរងដោយអ្នកនៅរស់រានមានជីវិតពីអំពើហឹង្សាផ្លូវភេទ និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅរបបខ្មែរក្រហមនៅឡើយទេ សូម្បីតែស្ត្រីជាជនរងគ្រោះពីការរំលោភសេពសន្ថវៈ ការរៀបការដោយបង្ខំ ការធ្វើទារុណកម្មផ្លូវភេទក្នុងចំណោមបទឧក្រិដ្ឋផ្សេងទៀត ក៏មិនទាន់ទទួលបានដំណោះស្រាយផងដែរ។

១៧. ជនប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ មិនទាន់ត្រូវបានកាត់ទោសនៅឡើយ។ដោយសារអណត្តិតុលាការខ្មែរក្រហមមានកំណត់ ដូចនេះមិនអាច និងនឹងមិនកាត់ទោសពួកគេបានទេ។ តែទោះជាយ៉ាងណា យើងយល់ថាឧក្រិដ្ឋជនទាំងនេះ ត្រូវមានករណីយកិច្ចទទួលស្គាល់នូវការពិតនៃការប្រើអំពើហឹង្សាលើស្ត្រីដោយរបបខ្មែរក្រហម មានករណីយកិច្ចទទួលស្គាល់ថាមានជនរងគ្រោះ និងធានាថាបទឧក្រិដ្ឋទាំងនេះត្រូវបានចងក្រងយ៉ាងម៉ត់ចត់ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ។

## អនុសាសន៍

១៨. យើងស្នើឲ្យគណៈកម្មាធិការនេះពិចារណាលើអនុសាសន៍ដូចខាងក្រោម:

*១. បង្កើតឲ្យមានផែនការលំអិតដើម្បីឆ្លើយតប បន្ទាប់ពីទទួលបានអនុសាសន៍ក្នុងរបាយការណ៍ថ្មីៗរបស់ដៃគូរដើម្បីការបង្ការ។ ផែនការនេះគួររួមបញ្ចូលកម្មវិធីច្បាស់លាស់ផ្សេងៗដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គមដែលពាក់ព័ន្ធនឹងទម្លាប់ទទួលយកអំពើហិង្សា កម្មវិធីលើកកម្ពស់បុរសល្អគ្មានអំពើហិង្សា និងបញ្ឈប់វប្បធម៌និទណ្ឌភាពចំពោះជនប្រព្រឹត្តិបទរំលោភសេពសន្ថវៈ។*

*២. ការបង្កើតកម្មវិធីដើម្បីស្តារនីតិសម្បទាដែលរួមមានកញ្ចប់ថវិកាចំណាយលើសេវាកម្ម*

*ឯកទេសនានាសំរាប់អ្នកនៅរស់រានមានជីវិតពីអំពើហឹង្សាពាក់ព័ន្ធនឹងយេនឌ័រនៅកំឡុងពេលជម្លោះកំពុងកើតឡើង ដូចជាសេវាកម្មសុខភាព សេវាផ្តល់ប្រឹក្សា និងជំនួយផ្នែកច្បាប់។*

*៣. ចាត់ឲ្យមានការសិក្សាផ្លូវការមួយដើម្បីឈានទៅចងក្រងជាឯកសារនូវបទឧក្រិដ្ឋពីអំពើហឹង្សាផ្លូវភេទ និងអំពើហឹង្សាពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងរបបខ្មែរក្រហម និងគាំទ្រយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីបទពិសោធន៍អតីតកាលនៃអ្នករស់រានមានជីវិត ដើម្បីកាច់បំបាក់ភាពស្ងៀមស្ងាត់ និងបង្ហាញពីដើមហេតុនៃអំពើហឹង្សាលើស្ត្រី។*

*៤. បែងចែកធនធាន ភ្នាក់ងារ និងជំនួយគាំទ្រដល់ប្រព័ន្ធ ត្រួតពិនិត្យ និង ការរាយការណ៍ពីអំពើហឹង្សាក្នុងគ្រួសារនៅតាមក្រសួងដែលពាក់ព័ន្ធទាំងអស់។*

## កិច្ចគាំពារស្ត្រីនៅកន្លែងធ្វើការ

### -អ្នកបំរើការងារតាមផ្ទះ

១៩. ទោះបីជាក្នុងរដ្ឋធម្មនុញ្ញបានចែងថា កិច្ចការពារនូវសិទ្ធិស្មើគ្នាក្នុងការប្រកបរបរ (មាត្រា ៣៦) ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ (មាត្រា ១..) បង្កឲ្យមានការរើសអើងលើស្ត្រី ដោយអ្នកបំរើការងារតាមផ្ទះមិនទទួលបានកិច្ចគាំពារស្មើតែទាំងអស់នៅក្នុងច្បាប់ការងារ។ក្របខ័ណ្ឌច្បាប់មានភាពទន់ខ្សោយនេះហើយ ដែលកំហិតការទទួលបាននូវយុត្តិធម៌ចំពោះអ្នកធ្វើការតាមផ្ទះ ថែមទាំងជំរុញឲ្យពួកគេងាយនឹងរងការរំលោភបំពាន ការបៀតបៀន និងអំពើហឹង្សាច្រើនជាងគេ។ ក្មេងស្រីមានចំណេះដឹងតិចតួចមកពីជនបទជាអ្នកងាយរងគ្រោះខ្លាំងជាងគេ។

២០. នៅក្នុងច្បាប់ការងារកម្ពុជា ស្ត្រីមានសិទ្ធិឈប់សំរាកលំហែលមាតុភាពដោយទទួលបានប្រាក់ឈ្នួលក្រោមលក្ខខណ្ឌថាស្ត្រីមានផ្ទៃពោះបានបំរើការងារជាប់លាប់រយពេលមួយឆ្នាំ (មាត្រា ១៨៣)។ បទបញ្ញត្តិនេះមានលក្ខណៈរើសអើងលើស្ត្រីខាងផ្នែកការងារ និងកំហិតសិទ្ធិ និងអត្ថប្រយោជន៍នានារបស់កម្មករក្រោមលេះកិច្ចសន្យាខ្លី បន្ទាប់ប្រើការបញ្ឈប់ពីការងារ។

### កម្មករចំណាកស្រុកបំរើការងារតាមផ្ទះ

២១. ដោយហេតុថាកម្មករស្ត្រីចំណាកស្រុកធ្វើការតាមផ្ទះមិនត្រូវបានគេអនុញ្ញាតឲ្យជួបពួក

គាត់ងាយរងនូវការរំលោភបំពាន និងការកេញប្រវ័ញ្ច។ ជាទូទៅ កម្មករស្ត្រីកម្ពុជាចំណាកស្រុកបំរើការងារតាមផ្ទះមិនត្រូវបានការពារដោយច្បាប់ការងារនៅក្នុងប្រទេសដែលទទួលយកពួកគាត់ឲ្យធ្វើការនោះឡើយ។ ស្ត្រីជាច្រើនត្រូវបង្ខំឲ្យចុះកិច្ចសន្យាធ្វើជាអ្នកបំរើដែលតម្រូវឲ្យបង់ថ្លៃសេវាកម្មទៅឲ្យភ្នាក់ងារជ្រើសរើសពលករ។ ជារឿយៗ កម្មករចំណាកស្រុកធ្វើការតាមផ្ទះមិនត្រូវបានអនុញ្ញាតឲ្យទាក់ទងជាមួយក្រុមគ្រួសាររបស់ពួកគេ។ ពួកគេបានរាយការណ៍ពីការទទួលរងបញ្ហាផ្លូវចិត្ត រំលោភបំពានលើផ្លូវកាយ និងផ្លូវភេទ ទន្ទឹមនឹងការប្រឈមទាំងនេះ ពួកគេទទួលបានប្រាក់ឈ្នួលទាប និងរយៈពេលធ្វើការច្រើនម៉ោង។

២២. កម្មករស្ត្រីកម្ពុជាបំរើការងារតាមផ្ទះដែលបានវិលត្រឡប់មកវិញ បានរងការរំលោភបំពានពីថៅកែរបស់ពួកគាត់ផ្ទាល់ ហើយពួកគេទទួលជំនួយតិចតួចពីប្រព័ន្ធតុលាការ។ គ្មានប្រព័ន្ធត្រួតពិនិត្យ គ្មានការអនុវត្តន៍ច្បាប់ដែលគ្រប់គ្រងទៅលើកម្មករចំណាកស្រុកបំរើការងារតាមផ្ទះ និងគ្មានយន្តការដោះស្រាយបណ្តឹងដើម្បីឲ្យកម្មករដែលទទួលរងការរំលោភបំពាន ឬជួញដូរអាចប្រើប្រាស់បាននៅឡើយទេ។ បើទោះជាខ្វះកិច្ចការពារជាមូលដ្ឋានក៏ដោយ ក៏មានកម្មករមួយចំនួនធំនៅតែបន្តធ្វើចំណាកស្រុក។ បើទោះជាមានការហាមឃាត់លើការបញ្ជូនកម្មករបំរើការងារតាមផ្ទះទៅប្រទេសម៉ាឡេស៊ីក៏ដោយ ក៏នៅមានកម្មការជាច្រើនបំរើការងារតាមផ្ទះនៅក្រៅប្រទេសដែរ។ បច្ចុប្បន្ន រដ្ឋាភិបាលកំពុងគ្រោងបញ្ជូនពលករកម្ពុជាចំនួន ៥០០ នាក់ទៅប្រទេសសិង្ហបូរី ពលករទាំងនេះអាចប្រឈមនឹងគ្រោះថ្នាក់។

## អនុសាសន៍

២៣. យើងស្នើឲ្យគណៈកម្មាធិការពិចារណាលើអនុសាសន៍ដូចខាងក្រោមៈ

*១. សូមឲ្យផ្តល់សច្ចាប័នឲ្យបានឆាប់រហ័សលើអនុសញ្ញា ILO ១៨៩។*

*២. ស្នើឲ្យចាត់វិធានការបន្ទាន់លើការធ្វើវិសោធនកម្មច្បាប់ការងារឆ្នាំ ១៩៩៧ ដើម្បីផ្តល់កិច្ចគាំពារដល់ស្ត្រី និងកម្មករបំរើការងារតាមផ្ទះ ព្រមទាំងបង្កើតឲ្យមានរាល់វិធានការចាំបាច់ទាំងឡាយដើម្បីធានាឲ្យមានការអនុវត្តន៍ច្បាប់ការងារនេះ។*

*៣. ចាត់រាល់វិធានការចាំបាច់ទាំងអស់ដើម្បីការពារសិទ្ធិកម្មករកម្ពុជាដែលបំរើការងារតាមផ្ទះនៅគ្រប់ដំណាក់កាលក្នុងការធ្វើទេសន្តរប្រវេសន៍ៈ ការរៀបចំឯកសារ ពេលបញ្ជូនពលករ ពេលមកដល់ និងពេលវិលត្រឡប់មកវិញ។*

**២៤.** សូមថ្លែងអំណរគុណចំពោះការពិចារណាយ៉ាងយកចិត្តទុកដាក់របស់លោក លោកស្រីទៅលើចំណុចទាំងនេះ។ យើងមានសេចក្តីសោមនស្ស និងត្រៀមខ្លួនឆ្លើយសំនួរ ព្រមទាំងផ្តល់ពត៌មានលំអិតបន្ថែមទៀត។